មជ្ឈមណ្ឌលខេមរសិក្សា Center for Khmer Studies Centre d'Études Khmères

AMERICAN CORNER SIEM REAP

# សេចក្តីប្រកាសព័ត៌មាន
# ពិព័រណ៍សៀវភៅសៀមរាបនឹងបើកទ្វារស្វាគមន៍សាធារណជនថ្ងៃទី២៥ ខែមិថុនា

ជាលើកដំបូងក្នុងខេត្តសៀមរាប កម្មវិធីពិព័រណ៍សៀវភៅដែលរៀបចំដោយ **បណ្ណាល័យមជ្ឈមណ្ឌលខេមរសិក្សា** និង **បណ្ណាល័យអាមេរិក ខេត្តសៀមរាប** នឹងបើកទទួលសាធារណជនចូលរួម ដោយសេរី នៅថ្ងៃទី**២៥ ខែមិថុនា ឆ្នាំ២០២២** នៅបរិវេណ មជ្ឈមណ្ឌលខេមរសិក្សា ស្ថិតក្នុងវត្តដំណាក់ ខេត្តសៀមរាប ចាប់ពីម៉ោង៧ព្រឹក ដល់ម៉ោង៧ល្ងាច។

**អ្នកស្រី ឈ ស៊ីវឡេង** ប្រធានបណ្ណាល័យមជ្ឈមណ្ឌលខេមរសិក្សា មានប្រសាសន៍ថា កម្មវិពិព័រណ៍សៀវភៅនេះធ្វើឡើងក្រោមប្រធានបទ «**ចាប់ផ្តើមការអានពីពួកយើង**»។ អ្នកស្រីបន្តថា គោលបំណងចម្បងក្នុងការរៀបចំព្រឹត្តិការណ៍នេះឡើង គឺដើម្បីជម្រុញទឹកចិត្តដល់យុវជន ប្អូនៗសិស្សនិស្សិត និងសាធារណជន ឱ្យចាប់អារម្មណ៍កាន់តែខ្លាំងបន្ថែមទៀត ទៅលើការពង្រីកចំណេះដឹងរបស់ខ្លួន តាមរយៈការអានសៀវភៅ។

**អ្នកស្រី ឈ ស៊ីវឡេង៖** «កម្មវិធីពិព័រណ៍សៀវភៅសៀមរាប ដែលយើងខ្ញុំរៀបចំឡើងជាលើកដំបូងនេះ បានទទួលការចូលរួម និងគាំទ្រពី អ្នកនិពន្ធ អ្នកបោះពុម្ពផ្សាយ គ្រឹះស្ថានអប់រំ បណ្ណាល័យ និងបណ្ណាគារ ប្រមាណ៣០ស្ថាប័ន។ យើងខ្ញុំចង់ឱ្យព្រឹត្តិការណ៍នេះ ក្លាយទៅជាវេទិកាសម្រាប់ការអប់រំ និងវប្បធម៌ ដែលប្រមូលផ្តុំដោយសហគមន៍អ្នកសិក្សា អ្នកស្រលាញ់ការអាន និងសាធារណជនទាំងអស់ដើម្បី ចែករំលែកចំណេះដឹង និងលើកទឹកចិត្តគ្នាទៅវិញទៅមក ក្នុងការជម្រុញឱ្យការអានសៀវភៅក្លាយជាទម្លាប់»។

ក្រៅពីការតាំងបង្ហាញស្តង់ពិព័រណ៍ ដែលមានការលក់សៀវភៅបញ្ចុះតម្លៃ និងការផ្តល់ជូនពិសេសៗ កម្មវិធីពិព័រណ៍សៀវភៅសៀមរាប ក៏មានសកម្មភាពផ្សេងៗជាច្រើនទៀតដូចជា៖ កម្មវិធីចែករំលែកចំណេះដឹងអំពីការអាន កិច្ចពិភាក្សាអំពីគន្លឹះទទួលបានអាហារូបករណ៍ទាំងក្នុង និងក្រៅប្រទេស ដោយអតីតនិស្សិតអាហារូករណ៍ និងប្រធានកម្មវិធីអាហារូបករណ៍ សួនសៀវភៅកុមារ ទស្សនីយភាពសិល្បៈរបាំ និងចាប៉ីដងវែង ការលេងល្បែងកំសាន្តយករង្វាន់ ការបរិច្ចាគសៀវភៅ និងសកម្មភាពជាច្រើនផ្សេងទៀត។

អ្នកចូលរួមដាក់ស្តង់តាំងបង្ហាញក្នុងព្រឹត្តិការណ៍នេះរួមមាន៖ សៀមរាបបណ្ណាល័យ, បណ្ណាគារស៊ីប៉ា, អង្គការយសោធរ, វិទ្យាស្ថានវ៉ាអ៊ុលវ៉ាលេនប៊ឺកច្បាប់សិទ្ធិមនុស្ស និង មនុស្សធម៌អន្តរជាតិ, សារៈមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្វសានវ៉្វន, សំណេរ, ប៊្លូរ៉ូមេន បោះពុម្ពផ្សាយ, វិជ្ជាស្ថានបារាំងចុងបូព៌ាប្រទេស, វេហាស៍, អង្គការមជ្ឈមណ្ឌលសិក្សាបណ្តុះបណ្តាលកសាងសន្តិភាព និងដោះស្រាយទំនាស់, បណ្ណាល័យ ម៉េងលី ជេ. គួច, មណ្ឌលសិក្សាសាលារៀនកម្ពុជា, ធីសៀវភៅ Bookstore & Café, បណ្ណាល័យបញ្ញវន្ត, បណ្ណាគារ ទំព័រ និង អ្នក

និពន្ធសៀវភៅ បុគ្គលឆ្នើមរបស់កម្ពុជា, សហគមន៍ស្ត្រីកុដិសូរ, មណ្ឌលព័ត៌មានសាធារណៈ, គ្រឹះស្ថានហាតប៊ុក, សាកលវិទ្យាល័យអង្គរ, សមាគមអ្នកនិពន្ធខ្មែរ, ស្ថានទូត (ហាងកាហ្វេ)។

កម្មវិធីនេះទទួលការគាំទ្រដោយ នាយកដ្ឋានអប់រំសហរដ្ឋអាមេរិក ក្រុមប្រឹក្សាមជ្ឈមណ្ឌលស្រាវជ្រាវអាមេរិកក្រៅប្រទេស ព្រមទាំងទទួលការសហការគាំទ្រពី វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺកច្បាប់សិទ្ធិមនុស្ស និង មនុស្សធម៌អន្តរជាតិ (RWI) ក្រោមការឧបត្ថម្ភពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត។

**ពិព័រណ៍សៀវភៅខ្នាតតូចខេត្តសៀមរាប**

**ប្រធានបទ៖ “ចាប់ផ្តើមការអានពីពួកយើង”**

**ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ នៅបរិវេនមជ្ឈមណ្ឌលខេមរសិក្សា សៀមរាប**

| **សកម្មភាពនៅខាងក្នុងសាលប្រជុំមជ្ឈមណ្ឌលខេមរសិក្សា** | | |
|---|---|---|
| **ម៉ោង** | **កម្មវិធី** | **វាគ្មិន** |
| ៨:00 - ៨:១៥ | ចុះឈ្មោះ | |
| ៨:១៥ - ៨:៤៥ | បើកកម្មវិធីជាមួយនឹងបទបង្ហាញខ្លីទាក់ទងនឹងតួនាទីបណ្ណាល័យសម្រាប់ការសិក្សា ស្រាវជ្រាវ | អ្នកស្រី ឈ ស៊ីវឡេង<br>ប្រធានបណ្ណាល័យ<br>មជ្ឈមណ្ឌលខេមរសិក្សា |
| ៨:៤៥ - ៩:១៥ | សំណួរ_ចម្លើយ យករង្វាន់អាវយឺត | |
| **សម្រាក ៣០នាទី** | | |
| ៩:៤៥ - ១០:៤៥ | កិច្ចពិភាក្សាអំពី គន្លឹះទទួលបានអាហារូបករណ៍ ទាំងក្នុង និងក្រៅប្រទេស | 1 - YSEALI<br>2 - YSEALI Academic<br>3 - TEA Program<br>4 - SEAYLP<br>5 - UGRAD<br>6 - Junior Fellowship Program (CKS)<br>7 - Raoul Wallenberg Institute |
| សំនួរ ចម្លើយ ៣០នាទី ១០:៤៥ ព្រឹក - ១១:១៥ ព្រឹក | | |
| **សម្រាកអាហារថ្ងៃត្រង់** | | |
| ២:៣០ - ៤:៣០ | បាឋកថាស្តីអំពី ហេតុអ្វីចាំបាច់អានសៀវភៅ? | អ្នកឧកញ៉ា បណ្ឌិត គួច ម៉េងលី |

**សកម្មភាពខាងក្រៅ ការតាំងពិព័រណ៍ ម៉ោង៧ព្រឹក ដល់ម៉ោង ៧ល្ងាច**

**បណ្ណាល័យ**

- បណ្ណាល័យមជ្ឈមណ្ឌលខេមរសិក្សា
- សកម្មភាពកុមារ (ការនិទានរឿង, គូររូប, ផាត់ពណ៌)
- មជ្ឈមណ្ឌលទំនាក់ទំនងព័ត៌មានសាធារណៈ
- បណ្ណាល័យអាមេរិក
- មណ្ឌលសិក្សាសាលារៀនកម្ពុជា
- សាកលវិទ្យាល័យអង្គរ
- បណ្ណាល័យ ម៉េងលី ជេ. គួច
- សៀមរាបបណ្ណាល័យ
- វិជ្ជាស្ថានបារាំងចុងបូព៌ាប្រទេស
- សារមន្ទីរព្រះស្រីឦសានវរ្ម័ន (ស.ស.រ)
- បណ្ណាល័យចល័តស៊ីប៉ា
- បណ្ណាល័យបញ្ញវន្ត

**បណ្ណាគារ**

- ធីសៀវភៅ
- បណ្ណាគារទំព័រ និងអ្នកនិពន្ធសៀវភៅបុគ្គលឆ្នើមរបស់កម្ពុជា

**អ្នកនិពន្ធ និងបោះពុម្ពផ្សាយ**

- សមាគមអ្នកនិពន្ធខ្មែរ
- អង្គការស៊ីប៉ា
- អង្គការយសោធរ
- គ្រឹះស្ថានហាតប៊ុក
- ប៊្លូម៉េន បោះពុម្ពផ្សាយ
- សំណេរ
- វេហាស៍

**ស្ថាប័នផ្សេងទៀត**

- អង្គការមជ្ឈមណ្ឌលសិក្សាបណ្តុះបណ្តាលកសាងសន្តិភាព និងដោះស្រាយទំនាស់ (CPCS) (អង្គការ)
- វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនបឺកច្បាប់សិទ្ធិមនុស្ស និង មនុស្សធម៌អន្តរជាតិ (RWI)
- ស្តង់ចែករំលែកសៀវភៅ (ផ្តល់មួយ ទទួលយកមួយ)
- សហគមន៍ស្ត្រីកុដិសូរ (ស្តង់វត្ថុអនុស្សាវរីយ៍)
- ស្ថានទូតកាហ្វេ (ស្តង់លក់កាហ្វេ)

**ទស្សនីយភាពសិល្បៈ ម៉ោង ៤:៣០ ដល់ម៉ោង ៦:៣០ ល្ងាច**

- ការសម្តែងចាប៉ីដងវែង ដោយសិល្បករ ឆុន តុលា
- ការសម្តែងរបាំ និងភ្លេងប្រពៃណី ដោយក្រុមរបាំមជ្ឈមណ្ឌលជាតិយុវជនកម្ពុជា